# ឧបសម្ព័ន្ធទី ២: លក្ខណៈវិនិច្ឆ័យ សន្ទស្សន៍ និង កំរិតនៃភាពក្រីក្រ

## លក្ខណៈនៃទីកន្លែង

| លក្ខណៈវិនិច្ឆ័យ | សន្ទស្សន៍ | ប្រភពពតិមាន |
|---|---|---|
| ជំរាល | ជំរាលខ្លាំង-ចោត<br>ជំរាលមធ្យម<br>រាបស្មើ | ផែនទីចំណោត់ថ្នាក់ទីជំរាល |
| គុណភាពជីជាតិ ដី | ទាប<br>មធ្យម<br>ខ្ពស់ | ផែនទីគុណភាពជីជាតិ ដី |
| គំរបព្រៃ | ពុំមានព្រៃ<br>ព្រៃរេចរិល<br>ព្រៃនៅល្អ | ផែនទីគំរបព្រៃ |

## កំរិតនៃការរុករានទន្រ្ទានធនធាន

| លក្ខណៈវិនិច្ឆ័យ | សន្ទស្សន៍ | ប្រភពពតិមាន |
|---|---|---|
| កំរិតនៃការរុករានទន្រ្ទាន | ដោយការកសាងផ្លូវថ្នល់ និង ភូមិករ (ខ្ពស់)<br>ដោយភូមិករឬដោយការកសាងផ្លូវថ្នល់(មធ្យម)<br>គ្មាន | ផែនទីកំរិតនៃការរុករានទន្រ្ទានធនធាន |

# ភាពក្រីក្រ

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងប្រកាន់យកនូវផែនទីនៃភាពក្រីក្រដែលរៀបចំឡើងដោយក្រសួងផែនការ និងអង្គការស្បៀងអាហារពិភពលោក (២០០២) សំរាប់ជាឧបករណ៍ណែនាំក្នុងការចែកចាយប្រភពធនធាន។ ផែនទីនៃ ភាពក្រីក្រ និង ក៏រិតនៃភាពក្រីក្រនេះ ត្រូវបានប្រើប្រាស់នៅក្នុងគោលការណ៍ណែនាំនេះ។ ដោយប្រើប្រាស់ផែនទីនេះរួមគ្នាជាមួយនឹងធនធានព្រៃឈើនិងទឹក គេអាចធ្វើការឧបមាថាប្រជាជនដែលរស់នៅក្បែរប្រភពធនធានធម្មជាតិមានលទ្ធភាពច្រើនជាងក្នុងការចូលទៅក្នុងតំបន់ទាំងនោះដើម្បីរុករកផលព្រៃឈើ ត្រី ហើយលើសពីនេះទិន្នផលស្រូវរបស់ពួកគេក៏ខ្ពស់ជាង ដូច្នេះពួកគេទាំងនោះមានជីវភាពប្រសើរជាងអ្នកដែលរស់នៅឆ្ងាយពីប្រភពធនធាន។ តំបន់ដែលមានក៏រិតក្រីក្រខ្លាំង ហើយថិតនៅឆ្ងាយពីប្រភពធនធានព្រៃឈើនិងទឹក ត្រូវបានចាត់ទុកថាមានអាទិភាពខ្ពស់ជាងគេ នៅក្នុងគោលការណ៍ណែនាំនេះ។

| លក្ខណៈវិនិច្ឆ័យ | សន្ទស្សន៍ | ទំងន់ | ប្រភពពត៌មាន |
|---|---|---|---|
| ក៏រិតនៃភាពក្រីក្រ (WFP) | > ៧៥ ភាគរយ<br>២៥ - ៧៥ ភាគរយ<br>< ២៥ ភាគរយ | ៣<br>២<br>១ | ផែនទី ក៏រិតនៃភាពក្រីក្រថ្នាក់ឃុំ-សង្កាត់ |
| លទ្ធភាពក្នុងការប្រើប្រាស់ធនធានព្រៃឈើ | > ៥ គម<br>< ៥ គម | ២<br>១ | ផែនទីគំរបព្រៃ |
| លទ្ធភាពក្នុងការប្រើប្រាស់ធនធានទឹក | > ៥ គម<br>< ៥ គម | ២<br>១ | ផែនទីគំរបព្រៃ<br>ផែនទីចំណាត់ថ្នាក់ទីជំរាល |

**ការដាក់ទំងន់:**

ប្រព័ន្ធនេះត្រូវបានរៀបចំឡើងដើម្បីជួយកំណត់តំបន់ដែលមានអាទិភាពសំរាប់ការងារដាំដើមឈើ។ សន្ទស្សន៍និមួយៗត្រូវបានកំណត់ដោយពិន្ទុមួយ ហើយនៅពេលបូកបញ្ចូលគ្នាទាំងអស់គេនឹងបានតួលេខមួយដែលកំណត់នូវចំណាត់ថ្នាក់សមស្របមួយសំរាប់ទីតាំង។

**ចំណាត់ថ្នាក់:**

ខ្ពស់: ពិន្ទុ ៧

មធ្យម: ពិន្ទុពី ៥-៦

ទាប: ពិន្ទុពី ៣-៤